ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# គោលនយោបាយ
# ស្តីពី
# ការអភិវឌ្ឍវិជ្ជាជីវៈ
# ជាប្រចាំសម្រាប់បុគ្គលិកអប់រំ

ខែ មិថុនា ឆ្នាំ២០១៧

# បុព្វកថា

វិស័យអប់រំមានតួនាទីភារកិច្ចសំខាន់ណាស់ក្នុងការកសាងធនធានមនុស្សដើម្បីរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមពុទ្ធិ។ គ្រូបង្រៀន នាយកសាលា ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាលារៀន សម្ភារសិក្សា និងប្រព័ន្ធអប់រំសុទ្ធសឹងជាធនធានមូលដ្ឋាន សម្រាប់ដំណើរការអប់រំឱ្យមានប្រសិទ្ធភាព។ នៅក្នុងចំណោមកត្តាទាំងនេះ បុគ្គលិកអប់រំ ជាពិសេសនាយកសាលា គ្រូបង្រៀន គឺជាកត្តាគន្លឹះបំផុតក្នុងការកសាងធនធានមនុស្ស ដែលទាមទារឱ្យមានការយកចិត្តទុកដាក់លើកទឹកចិត្ត និងពង្រឹងសមត្ថភាពជាប្រចាំ។

ក្រសួងអប់រំ យុវជន និងកីឡា កសាងគោលនយោបាយស្តីពី **«ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ»** នេះឡើងក្នុងគោលបំណង លើកកម្ពស់សមត្ថភាពបំពេញការងាររបស់បុគ្គលិកអប់រំជាពិសេសការបង្រៀន និងរៀន ដើម្បីផ្តល់ឱកាសឱ្យបុគ្គលិកអប់រំគ្រប់កម្រិតបានចូលរួមអភិវឌ្ឍវិជ្ជាជីវៈគ្រប់គ្នាដោយសមធម៌ បណ្តុះវប្បធម៌ អភិវឌ្ឍវិជ្ជាជីវៈពេញមួយជីវិតការងារដល់បុគ្គលិកអប់រំនៅតាមអង្គភាព និងសាលារៀន និងចេះចែករំលែកចំណេះដឹង ជំនាញ បទពិសោធន៍ទៅវិញទៅមកនៅក្នុងសហគមន៍របស់ខ្លួន។

ខ្លឹមសារនៃគោលនយោបាយនេះរួមមាន ចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រ និងផែនការអនុវត្ត ដែលជាត្រីវិស័យសម្រាប់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំនៅក្នុងពេលបម្រើការងារ។ ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹម និងជឿជាក់ថា គ្រប់អង្គភាព ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល ផ្នែកឯកជនរួមទាំងបុគ្គលិកអប់រំនឹងចូលរួមយ៉ាងសកម្មក្នុងការជំរុញផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយស្តីពី **«ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ»** នេះឱ្យទទួលបានជោគជ័យ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិត ហង់ ជួន ណារ៉ុន

# មាតិកា


| | ទំព័រ |
|---|---|
| ១.សេចក្តីផ្តើម | ១ |
| ២. ចក្ខុវិស័យ | ១ |
| ៣. គោលបំណង | ២ |
| ៤. គោលដៅ | ២ |
| ៥. យុទ្ធសាស្រ្ត | ២ |
| ៦. ផែនការអនុវត្ត | ៤ |
| ៧. សេចក្តីសន្និដ្ឋាន | ៥ |
| សទ្ទានុក្រម | |

## ១. សេចក្ដីផ្ដើម

ការអភិវឌ្ឍប្រទេសឱ្យមានវឌ្ឍនភាព វិបុលភាព និងភាពថ្កុំថ្កើងរុងរឿងដំបូងបំផុតត្រូវកសាងធនធានមនុស្សដែលមានលក្ខណសម្បត្តិពេញលេញប្រកបដោយភាពរីកចម្រើនគ្រប់ផ្នែក ដោយមានតុល្យភាពរវាងវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា កាយសម្បទា និងមនសិការស្នេហាជាតិនិងមនុស្សជាតិ។

គ្រូបង្រៀនជាវិស្វករព្រលឹង។ការអប់រំប្រកបដោយគុណភាពខ្ពស់ទាមទារឱ្យគ្រូបង្រៀនមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ស្តង់ដារវិជ្ជាជីវៈតាមរយៈគោលនយោបាយអភិវឌ្ឍគ្រូបង្រៀនជាក់លាក់ យន្តការអភិវឌ្ឍវិជ្ជាជីវៈទាំងមុនពេល និងក្នុងពេលកំពុងបម្រើការងារដោយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការលើកទឹកចិត្តនានា។

គ្រូបង្រៀនត្រូវបានបណ្តុះបណ្តាលនៅតាមសាលាគរុកោសល្យមុននឹងចេញទៅបម្រើការងារ។ គ្រូបង្រៀនក៏បានទទួលការធ្វើវិក្រឹតការតាមរូបភាពផ្សេងៗផងដែរ មានជាអាទិ៍ ស្វ័យវិក្រឹតការ វិក្រឹតការនៅនឹងកន្លែង និងការបំប៉នផ្សេងៗទៀត ព្រមទាំងវគ្គវិក្រឹតការរៀបចំនៅតាមសាលាគរុកោសល្យ អង្គភាព និងស្ថាប័ននានា។ តាមនិន្នាការសកលលោក តំបន់ និងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា គ្រូបង្រៀនត្រូវការអភិវឌ្ឍវិជ្ជាជីវៈបន្ថែមទៀតតាមរយៈប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈដែលមានក្របខ័ណ្ឌជាក់លាក់ ភាពទាក់ទាញ និងនិរន្តរភាព។

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា និងអ្នកពាក់ព័ន្ធបានជំរុញលើកទឹកចិត្តធ្វើវិក្រឹតការនៅនឹងកន្លែង និងវិក្រឹតការមិនរៀបរយតាមគ្រប់រូបភាព ប៉ុន្តែប្រសិទ្ធភាពនៅមានកម្រិត មិនទាន់មានសង្គតិភាព និងមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងសម្រាប់ការអនុវត្តនៅឡើយ។ ការងារវិក្រឹតការកន្លងមកបានបំពេញតម្រូវការគ្រូបង្រៀនមួយភាគតូច និងមិនទាន់មានកាលកំណត់ជាក់លាក់ ព្រមទាំងមិនទាន់ផ្សារភ្ជាប់ទាំងស្រុងទៅនឹងប្រព័ន្ធវាយតម្លៃការបំពេញការងារ និងប្រព័ន្ធលើកទឹកចិត្តច្បាស់លាស់។

គោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ មានគោលបំណងរៀបចំបុគ្គលិកអប់រំឱ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងមានសក្តានុពលបំពេញការងាររហូតដល់ពេលបញ្ចប់អាជីព តាមរយៈកម្មសិក្សា ការហ្វឹកហាត់ ការធ្វើវិក្រឹតការ និងកម្មវិធីលើកកម្ពស់វិជ្ជាជីវៈដល់បុគ្គលិកអប់រំដែលកំពុងបំពេញការងារប្រកបដោយប្រសិទ្ធភាពខ្ពស់។

## ២. ចក្ខុវិស័យ

គោលនយោបាយនេះមានចក្ខុវិស័យបណ្តុះស្មារតីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំពេញមួយជីវិតការងារដល់បុគ្គលិកអប់រំគ្រប់រូប។

## ៣. គោលបំណង

គោលនយោបាយនេះមានគោលបំណងអភិវឌ្ឍបុគ្គលិកអប់រំឱ្យមានលក្ខណសម្បត្តិគ្រប់គ្រាន់និងមានសក្តានុពលស្របតាមតួនាទីភារកិច្ចរហូតដល់ពេលបញ្ចប់អាជីព។

## ៤. គោលដៅ

៤.១.ធានាឱ្យមានក្របខ័ណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ។

៤.២.ធានាថាបុគ្គលិកអប់រំគ្រប់រូបនឹងទទួលបានវគ្គវិក្រឹតការទៀងទាត់។

៤.៣.ធានាឱ្យមានការលើកទឹកចិត្តក្នុងការលើកកម្ពស់គុណវុឌ្ឍិបុគ្គលិកអប់រំ។

៤.៤.ធានាការផ្សារភ្ជាប់រវាងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពបុគ្គលិកអប់រំ។

៤.៥.ធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់បុគ្គលិកអប់រំ។

## ៥.យុទ្ធសាស្ត្រ

ដើម្បីសម្រេចចក្ខុវិស័យគោលបំណងនិងគោលដៅខាងលើយុទ្ធសាស្ត្រសំខាន់ៗដែលត្រូវអនុវត្តមានដូចខាងក្រោម៖

### ៥.១.កសាងលិខិតបទដ្ឋានគតិយុត្ត និងយន្តការសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- ពិនិត្យកែលម្អនិងរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់បុគ្គលិកអប់រំ
- រៀបចំយន្តការអនុវត្តនិងគាំទ្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ផ្តោតលើការងារវិក្រឹតការរៀបរយ និងការងារវិក្រឹតការនៅនឹងកន្លែង
- រៀបចំគណៈកម្មការ និងអនុគណៈកម្មការបច្ចេកទេសដើម្បីអនុវត្ត គាំទ្រ ពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយ
- រៀបចំផែនការសកម្មភាពជាក់លាក់ រួមមានកម្មវិធីលម្អិត ពេលវេលា និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ
- ផ្សព្វផ្សាយយន្តការ និងផែនការសកម្មភាពនៃការអនុវត្តគោលនយោបាយឱ្យបានទូលំទូលាយ
- ចងក្រងគ្រប់ខ្លឹមសារនៃវគ្គវិក្រឹតការនិងផ្សព្វផ្សាយតាមប្រព័ន្ធអេឡិចត្រូនិកសម្រាប់បុគ្គលិកអប់រំប្រើប្រាស់ធ្វើស្វ័យសិក្សានិងរៀបចំផែនការកែលម្អការសិក្សាផ្ទាល់ខ្លួន ។

### ៥.២.កំណត់ប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ

- វាយតម្លៃនិងគ្រប់គ្រងច្បាស់លាស់នូវគ្រប់សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីទទួលស្គាល់ជាផ្លូវការឬប្រគល់សញ្ញាបត្រសមមូល (មធ្យមសិក្សាទុតិយភូមិ បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ ...)

- កំណត់ពេលវេលាសម្រាប់ធ្វើវិក្រឹតការឱ្យបានជាក់លាក់
- រៀបចំប្រព័ន្ធវិក្រឹតការរៀបរយឱ្យមានភាពជាក់លាក់រៀងរាល់ ៥ឆ្នាំម្តង
- រៀបចំប្រព័ន្ធក្រេឌីតសម្រាប់វគ្គវិក្រឹតការគ្រប់រូបភាព
- ធ្វើបច្ចុប្បន្នភាពប្រព័ន្ធគ្រប់គ្រងទិន្នន័យធនធានមនុស្សជាប្រចាំ
- រៀបចំប្រព័ន្ធអភិវឌ្ឍគុណវុឌ្ឍិបុគ្គលិកអប់រំតាមគ្រប់រូបភាព (នៅនឹងកន្លែង កម្មវិធីបណ្តុះបណ្តាលពន្លឿន វគ្គបណ្តុះបណ្តាលរយៈពេលខ្លីសម្រាប់អ្នកមានសញ្ញាបត្រជាក់លាក់...)។

**៥.៣.កំណត់តម្រូវការនៃការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ**

- រៀបចំផែនការស្រាវជ្រាវនិងអភិវឌ្ឍសមត្ថភាពតាមអង្គភាពអប់រំ
- ស្រាវជ្រាវអំពីតម្រូវការអភិវឌ្ឍវិជ្ជាជីវៈ
- កំណត់មុខសញ្ញានិងខ្លឹមសារវិក្រឹតការគ្រប់ប្រភេទ
- កសាងផែនការសម្រាប់បណ្តុះបណ្តាលបុគ្គលិកអប់រំជំនាញស្របតាមតម្រូវការរបស់ក្រសួង/ជាតិ
- សិក្សាលម្អិត រៀបចំប្រកាស និងអនុវត្តប្រព័ន្ធគ្រូអម គ្រូជំនួយសម្រាប់វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស
- ផ្តល់អាទិភាពដល់ក្រុមគោលដៅ(គណៈគ្រប់គ្រងនិងគ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ) ទទួលការអភិវឌ្ឍវិជ្ជាជីវៈ លើកកម្ពស់សមត្ថភាពរបស់ខ្លួនឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រ។

**៥.៤.គ្រប់គ្រង និងអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ**

- ផ្តល់សុពលភាពគ្រប់ខ្លឹមសារនៃឯកសារវិក្រឹតការ ដោយផ្តោតលើ វិធីសាស្ត្របង្រៀន និងកម្មវិធីហ្វឹកហាត់
- រៀបចំប្រព័ន្ធគ្រប់គ្រងនៅនឹងកន្លែងសម្រាប់ការងារវិក្រឹតការគ្រប់ប្រភេទ
- ផ្តល់ការគាំទ្រគ្រូថ្មីឱ្យបានចូលរួមក្នុងយន្តការហ្វឹកហាត់នៅនឹងកន្លែងឱ្យបានទៀងទាត់
- អភិវឌ្ឍសមត្ថភាពគ្រូឧទ្ទេស អ្នកហ្វឹកហាត់បង្គោល អ្នកហ្វឹកហាត់តាមសាលា
- អភិវឌ្ឍសមត្ថភាពនាយកសាលារៀន ដោយផ្តោតលើ ការគ្រប់គ្រងផ្អែកលើសាលារៀន (ការគ្រប់គ្រងរដ្ឋបាល ការបង្រៀននិងរៀន ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក)
- រៀបចំថ្មី ពង្រឹង និងអនុវត្តយន្តការការគាំទ្របុគ្គលិកអប់រំនៅនឹងកន្លែង ដើម្បីបំពេញតម្រូវការនិងពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈ
- រៀបចំឱ្យមានការចែករំលែកឧត្តមានុវត្តន៍ និងនវានុវត្តន៍ពីសំណាក់បុគ្គលិកអប់រំមានស្នាដៃល្អ
- អភិវឌ្ឍសមត្ថភាពមន្ត្រីបង្គោលនៃអង្គភាពធនធានមនុស្សនៅថ្នាក់ជាតិនិងក្រោមជាតិ (ផែនការបន្តវេន សមធម៌យេនឌ័រក្នុងការអប់រំបច្ចេកទេស...)
- អភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនតាមជម្រើស តាមប្រព័ន្ធក្រេឌីតនៅនឹងកន្លែង សិក្សាពីចម្ងាយ វិក្រឹតការរយៈពេលខ្លីជាជំហានៗ វិក្រឹតការរយៈពេលវែង ផ្តល់អាហារូបករណ៍ បណ្តុះបណ្តាលដោយប្រើលិខិតបញ្ជាក់ និងកម្មវិធីវិក្រឹតការពន្លឿន

- បង្កើនគុណវុឌ្ឍិបុគ្គលិកអប់រំ គណៈគ្រប់គ្រងអប់រំនៅថ្នាក់កណ្តាលឱ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់
- ប្រើប្រាស់ការធ្វើវិក្រឹតការបែបក្រេឌីតសម្រាប់លើកទឹកចិត្តបុគ្គលិកអប់រំតាមគន្លងអាជីពបុគ្គលិកអប់រំ
- ពង្រឹងសមត្ថភាពអ្នកបណ្តុះបណ្តាល/បំប៉ន/បង្វឹក/ណែនាំផ្ទាល់ឱ្យដល់កម្រិតស្តង់ដាជាតិសមត្ថភាព/ក្របខណ្ឌគុណវុឌ្ឍិជាតិ។

**៥.៥.លើកទឹកចិត្ត និងរក្សាទុកគ្រូបង្រៀនឱ្យនៅក្នុងប្រព័ន្ធអប់រំ**

- លើកទឹកចិត្តបុគ្គលិកអប់រំដែលបានចូលរួមវគ្គវិក្រឹតការវិជ្ជាជីវៈគ្រប់ប្រភេទទាំងក្នុងនិងក្រៅប្រទេស
- គាំទ្រនិងផ្តល់ស្វ័យភាពដល់បុគ្គលិកអប់រំធ្វើសេចក្តីសម្រេចចិត្តអំពីស្វ័យសិក្សាកែលម្អការសិក្សាផ្ទាល់ខ្លួនសំដៅ អភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន យ៉ាងតិច ១០០ ម៉ោងក្នុង ១ ឆ្នាំ
- ទទួលស្គាល់ ផ្តល់រង្វាន់និងលាភការនានា ដល់បុគ្គលិកអប់រំដែលបានអភិវឌ្ឍវិជ្ជាជីវៈ ដោយផ្សារភ្ជាប់ជាមួយគន្លងអាជីពបុគ្គលិកអប់រំ

**៥.៦.អនុវត្តប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ**

- បង្កើតប្រព័ន្ធពិនិត្យតាមដាននិងវាយតម្លៃ ដំណើរការអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ ពីថ្នាក់ជាតិដល់ថ្នាក់ក្រោមជាតិ និងសាលារៀន
- សិក្សាផលប៉ះពាល់នៃការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំ
- បង្កើតនិងគ្រប់គ្រងប្រព័ន្ធរាយការណ៍អំពីការងារវិក្រឹតការ។

## ៦. ផែនការអនុវត្ត

**៦.១. ការបង្កើតយន្តការ**

ពង្រឹងយន្តការដែលមានស្រាប់ ឬបន្ថែមថ្មីគ្រប់កម្រិតភូមិសិក្សា ដើម្បីជំរុញការអនុវត្តការពិនិត្យតាមដាននិងវាយតម្លៃ ការលើកទឹកចិត្ត និងការផ្តល់អនុសាសន៍កែលម្អការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំះ

- រៀបចំគណៈកម្មការអនុគណៈកម្មការបច្ចេកទេស និងលេខាធិការដ្ឋាន ដើម្បីជួយណែនាំតម្រង់ទិស និងសម្របសម្រួលការអនុវត្តការងារអភិវឌ្ឍវិជ្ជាជីវៈ
- វិទ្យាស្ថានជាតិអប់រំ និងវិទ្យាស្ថានគរុកោសល្យ
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត ការិយាល័យបុគ្គលិកនិងបណ្តុះបណ្តាលមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាគរុកោសល្យនិងវិក្រឹតការខេត្ត និងអង្គភាពស្ថាប័នផ្សេងៗទៀត
- ការិយាល័យអប់រំយុវជន និងកីឡាក្រុងស្រុកខណ្ឌគ្រឹះស្ថានសិក្សាគ្រប់កម្រិត តាមរយៈក្រុមបំប៉ននិងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ជាអ្នកទទួលបន្ទុកអនុវត្តវិក្រឹតការ នៅនឹងកន្លែង និងការងារហ្វឹកហាត់។

### ៦.២. ការបង្កើតក្របខណ្ឌគតិយុត្ត

- ពង្រឹងនិងប្រើប្រាស់រចនាសម្ព័ន្ធដែលមានស្រាប់ដោយបន្ថែមតួនាទីនិងភារកិច្ចឬបង្កើតគណៈកម្មការថ្មីបន្ថែមទៀតដែលគណៈកម្មការនីមួយៗត្រូវកំណត់ដោយសេចក្ដីសម្រេចរបស់ក្រសួងអប់រំយុវជននិងកីឡា
- គណៈកម្មការខាងលើនេះត្រូវពិនិត្យឡើងវិញ កែសម្រួល រៀបចំលិខិតបទដ្ឋានគតិយុត្តថ្មីតាមការចាំបាច់ដើម្បីធានាការអនុវត្តគោលនយោបាយនេះឱ្យមានប្រសិទ្ធភាព។

### ៦.៣. ធនធានគាំទ្រ

ការអនុវត្តគោលនយោបាយនេះគប្បីត្រូវមានធនធានគាំទ្រ រួមមានធនធានមនុស្ស ធនធានសម្ភារៈធនធានថវិកា និងឯកសារសម្រាប់បម្រើឱ្យការងារហ្វឹកហាត់ ការងារវិក្រឹតការនៅនឹងកន្លែងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់មុខសញ្ញានីមួយៗ។អង្គភាពដែលពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដៃគូអភិវឌ្ឍត្រូវសហការគ្នាដោះស្រាយឱ្យទាន់ពេលវេលា។

### ៦.៤. យន្តការអនុវត្ត

ដើម្បីធានាការអនុវត្តគោលនយោបាយនេះឱ្យទទួលបានជោគជ័យនិងមានប្រសិទ្ធភាពគណៈកម្មការនានានិងអង្គភាពពាក់ព័ន្ធត្រូវះ

- សិក្សាក្របខ័ណ្ឌយុទ្ធសាស្ត្រគោលនយោបាយនីមួយៗ រួចធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់អ្នកពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ តាមគ្រប់រូបភាព
- រៀបចំផែនការសកម្មភាពអនុវត្តគោលនយោបាយនេះទាំងរយៈពេលខ្លី រយៈពេលមធ្យម និងធ្វើការពិគ្រោះយោបល់ពីគ្រប់អ្នកពាក់ព័ន្ធសំដៅធានាឱ្យមានសុខដុមនីយកម្ម ទាំងដំណើរការអនុវត្ត ទាំងមូលនិធិទ្រទ្រង់និងការគ្រប់គ្រង
- ពិនិត្យឡើងវិញនិងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយនេះ ព្រមទាំងផ្ដល់អនុសាសន៍កែលម្អឱ្យទាន់ពេលវេលា
- ធ្វើបច្ចុប្បន្នភាព ផែនការការងារទាំងយន្តការអនុវត្ត ទាំងតម្រូវការធនធាន និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ។

## ៧. សេចក្តីសន្និដ្ឋាន

គោលនយោបាយស្ដីពី ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ បានបង្ហាញពីចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រដល់អង្គភាព ស្ថាប័នពាក់ព័ន្ធ យកទៅរៀបចំផែនការសកម្មភាពសម្រាប់ធ្វើការអភិវឌ្ឍវិជ្ជាជីវៈបុគ្គលិកអប់រំក្នុងពេលបម្រើការងារ សំដៅលើកកម្ពស់គុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ ស្តង់ដារវិជ្ជាជីវៈរបស់គ្រូបង្រៀន និងលទ្ធផលសិក្សារបស់សិស្សដែលជាធនធានមនុស្សចាំបាច់របស់ប្រទេសជាតិ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមនិងជឿជាក់ថា គ្រប់អង្គភាព ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍសង្គមស៊ីវិល ផ្នែកឯកជន និងបុគ្គលិកអប់រំនឹងចូលរួមចំណែកក្នុងការជំរុញផ្សព្វផ្សាយ គាំទ្រ និងអនុវត្តគោលនយោបាយនេះឱ្យបានជោគជ័យ។

# សទ្ទានុក្រម

| | |
|---|---|
| ការអភិវឌ្ឍវិជ្ជាជីវៈ | ជាការបណ្ដុះបណ្ដាលជំនាញ ការអប់រំផ្លូវការ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ក្នុងគោលបំណងគាំទ្រដល់បុគ្គលិកអប់រំ ដើម្បីលើកកម្ពស់វិជ្ជាជីវៈសមត្ថភាព ជំនាញ និងប្រសិទ្ធផល។ |
| កម្មវិធីហ្វឹកហាត់ | ជាកម្មវិធីគាំទ្រសម្រាប់គ្រូចេញថ្មី ដែលនឹងត្រូវផ្ដល់តាមរូបភាព ២ គឺ អ្នកហ្វឹកហាត់បង្គោល អ្នកហ្វឹកហាត់តាមសាលារៀន។ កម្មវិធីហ្វឹកហាត់នឹងផ្ដោតលើការអភិវឌ្ឍ ចំណេះដឹងខ្លឹមសារ (content knowledge) ដែលមានសមាសធាតុ២គឺ ចំណេះដឹងមុខវិជ្ជា និងការសិក្សាគរុកោសល្យ(ការសិក្សាគរុកោសល្យ តាមរយៈកម្មវិធីសិក្សាសាលារៀន និងវិធីសាស្ត្របង្រៀន)។ |
| ការគ្រប់គ្រងផ្អែកលើសាលារៀន | ជាទស្សនទាននៃការគ្រប់គ្រងសាលារៀន ដោយផ្ដោតលើ គណនេយ្យភាព និងអភិបាលកិច្ចនៅកម្រិតសាលារៀន ដោយមានការចូលរួម។ ទស្សនទាននេះឈរលើមូលដ្ឋាននៃ ការគ្រប់គ្រងរដ្ឋបាល ការបង្រៀននិងរៀន ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងបុគ្គលិក។ |